# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០១២៣.រថ.បគអថ.ប្រក

## ប្រកាស
## ស្តីពី
## ការកំណត់ទំហំប្រព័ន្ធ និងទំហំកូតា នៃថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា សម្រាប់ឆ្នាំ ២០២៤

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ ០០៩៧ រថ.អថ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២ ស្តីពីការបង្កើតគណៈកម្មការស្ថាប័នដើម្បីរៀបចំគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា
- បានឃើញប្រកាសលេខ ០១៥៩ រថ.ថកថ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ស្តីពី ការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ ១.**_

កំណត់ប្រភេទ នៃប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលសម្រាប់ការអនុវត្តនៅឆ្នាំ២០២៤ ទៅតាមទំហំអានុភាពដំឡើង នៃប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល តាមទីតាំងនីមួយៗដូចខាងក្រោម៖

១. ប្រភេទតូច ដែលមានអានុភាពដំឡើងមិនលើសពី 10 kWac

២. ប្រភេទមធ្យម ដែលមានអានុភាពលើសពី 10 kWac ដល់ 100 kWac

៣. ប្រភេទធំ ដែលមានអានុភាពដំឡើងលើសពី 100 kWac ឡើងទៅ។

**ប្រការ ២._**

ផ្តល់កូតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់អនុវត្តនៅឆ្នាំ២០២៤ ក្នុងទំហំពេញលេញដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញលិខិតអនុញ្ញាតឱ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ដែលបានដំឡើងថាមពលពន្លឺព្រះអាទិត្យលើដំបូលរួចហើយ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតឱ្យដំឡើងដោយអគ្គិសនីកម្ពុជា និងបានចុះកិច្ចសន្យាប្រើប្រាស់ថ្លៃថាមពលពន្លឺព្រះអាទិត្យលើដំបូល

២- អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតឱ្យដំឡើងរួចហើយ ប៉ុន្តែមិនទាន់បានចុះកិច្ចសន្យាប្រើប្រាស់ថ្លៃថាមពលពន្លឺព្រះអាទិត្យលើដំបូល

៣- អ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតឱ្យដំឡើងរួចហើយ ប៉ុន្តែត្រូវផ្អាកនីតិវិធីវិញដោយសារអត្រាថ្លៃអានុភាព ( Capacity Charge )

៤- អ្នកប្រើប្រាស់ដែលបានដំឡើងប្រព័ន្ធរួចហើយ និងបានធ្វើស្វ័យប្រកាសទៅអ្នកផ្គត់ផ្គង់អគ្គិសនីឯកជន ឬអគ្គិសនីកម្ពុជា។

**ប្រការ ៣._**

អ្នកប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានដំឡើងថាមពលពន្លឺព្រះអាទិត្យលើដំបូលរួចហើយ ក្នុងលក្ខខណ្ឌដូចបានចែងក្នុងប្រការ ២ ខាងលើ មុនថ្ងៃប្រកាសនេះចូលជាធរមានត្រូវបានចាត់ទុកថាជា "**អ្នកប្រើប្រាស់អគ្គិសនីដែលបានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលរួចហើយ**" ស្របតាមប្រកាសលេខ ០១៥៩ រថ.ថកថ.ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍សម្រាប់ការអនុញ្ញាតឱ្យប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជារបស់ក្រសួងរ៉ែ និងថាមពល។

**ប្រការ ៤._**

អ្នកប្រើប្រាស់អគ្គិសនីអាចទទួលបានកូតាអនុញ្ញាតឱ្យដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែអ្នកប្រើប្រាស់អគ្គិសនីនោះបានបំពេញបែបបទស្នើសុំ និងទទួលបានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិ នីតិវិធី និងគោលការណ៍ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

**ប្រការ ៥._**

ប្រធានអង្គភាព និងស្ថាប័នពាក់ព័ន្ធទាំងអស់រួមមាន៖ អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែ និងថាមពលរាជធានី/ខេត្ត អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុករួមគ្នាអនុវត្តប្រកាសនេះឱ្យបានសុក្រឹត និងមានប្រសិទ្ធភាព។

**ប្រការ ៦.**_

ប្រកាស សេចក្តីសម្រេច និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.**_

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ_រតនៈ**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ